As delivered, 7 July 2022, 3:20PM

# សេចក្តីរាយការណ៍
# ដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ស្តីពីលទ្ធផលនៃទស្សនកិច្ចលើកទី២ របស់ប្រេសិតពិសេស
# នៃប្រធានអាស៊ាន ឆ្នាំ២០២២ ស្តីពីមីយ៉ាន់ម៉ា
# ពីថ្ងៃទី៣០ មិថុនា-០២ កក្កដា ឆ្នាំ២០២២

នៅទីស្តីការក្រសួងការបរទេស, ភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

*******

- **ឯកឧត្តម លោកជំទាវ ឯកអគ្គរាជ/រដ្ឋទូត សមាជិកអង្គទូត**
- **សមាជិកអ្នកសារព័ត៌មាន លោក លោកស្រី អ្នកនាង កញ្ញា**

១. ជាបឋម ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចូលរួមក្នុងសេចក្តីរាយការណ៍ស្តីពីលទ្ធផលនៃទស្សនកិច្ចលើកទី២របស់ខ្ញុំ នៅមីយ៉ាន់ម៉ា ក្នុងនាមជាប្រេសិតពិសេសនៃប្រធានអាស៊ានស្តីពីមីយ៉ាន់ម៉ា នារសៀលនេះ។ ខ្ញុំជឿជាក់ថា អ្នកទាំងអស់គ្នាបានអានសេចក្តីប្រកាសព័ត៌មាន ដែលបានរៀបរាប់ដោយត្រួសៗអំពីលទ្ធផលនៃដំណើរទស្សនកិច្ចនេះ រួចហើយ។

២. ដូចទស្សនកិច្ចលើកទី១ដែរ បេសកកម្មលើកទី២នេះ មានគោលបំណងជំរុញវឌ្ឍនភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច (5PC) ដូចជាការបញ្ឈប់អំពើហិង្សា ការពន្លឿនការផ្តល់ជំនួយមនុស្សធម៌ និងកម្មវិធីចាក់វ៉ាក់សាំងរួមគ្នា ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការផ្តល់ជំនួយមនុស្សធម៌របស់

អាស៊ានទៅមីយ៉ាន់ម៉ា កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ នៅទីក្រុងភ្នំពេញ និងការបង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចសន្ទនានយោបាយមួយប្រកបដោយបរិយាប័ន្ន។

៣. យើងបានរៀបចំឡើងយ៉ាងប្រុងប្រយ័ត្ននៅមុនពេលចេញដំណើរ នូវបញ្ជីរាយនាមបុគ្គល ស្ថាប័ន និងតួអង្គពាក់ព័ន្ធដែលត្រូវជួប ប្រធានបទដែលត្រូវលើកឡើង សំណួរដែលត្រូវសួរ លទ្ធភាពក្នុងការស្វែងរក និងលទ្ធផលរំពឹងទុករបស់ទស្សនកិច្ចនេះ។ ក្រុមការងារនាំមុខដែលដឹកនាំដោយ**ឯកឧត្តមរដ្ឋលេខាធិការ គង់ ភោគ** ប្រធានការិយាល័យប្រេសិតពិសេសនៃប្រធានអាស៊ាន បានទៅមីយ៉ាន់ម៉ាដើម្បីធ្វើការងារសម្របសម្រួលជាមុន ព្រមទាំងធ្វើការចរចាជាមួយរដ្ឋបាលក្រុងណៃពិដោ ពាក់ព័ន្ធនឹងភាពលម្អិតនៃកម្មវិធីទស្សនកិច្ចនេះ។ ក្រុមការងាររបស់យើងពិតជារៀបចំការងារខាងលើនេះបានល្អណាស់។

## I. តើតួអង្គណាខ្លះដែលខ្ញុំ និងក្រុមការងារបានជួប?

៤. យើងបានជួបជាមួយតួអង្គមួយចំនួនមកពីក្រុមប្រឹក្សារដ្ឋបាលរដ្ឋ (SAC) ដែលរួមមាន ឯកឧត្តមនាយឧត្តមសេនីយ៍ **មីន អោងឡាំង** ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ, ឯកឧត្តមរដ្ឋមន្ត្រីការបរទេស **វ៉ុនណា ម៉ោងល្វីន**, ឯកឧត្តម **កូ កូឡាំង** ប្រធានក្រុមការងារមីយ៉ាន់ម៉ាទទួលបន្ទុកជំនួយមនុស្សធម៌អាស៊ាន រួមជាមួយនឹងរដ្ឋមន្ត្រីសុខាភិបាល និងរដ្ឋមន្ត្រីសុខុមាលភាពសង្គម និងឯកឧត្តមឧត្តមសេនីយ៍ឯក **យ៉ា ពៀ** ប្រធានគណៈកម្មាធិការសាមគ្គីភាពជាតិ និងការបង្កើតសន្តិភាព (NSPNC)។

៥. ក្រុមការងារយើង ក៏បានជួបជាមួយនឹងអន្តរការី(Interlocutors) មួយចំនួនទៀត ជាពិសេសតួអង្គមួយចំនួនដែលមិនមែនមកពីក្រុមប្រឹក្សារដ្ឋបាលរដ្ឋ (SAC) ដែលរួមមាន អង្គការប្រដាប់អាវុធជនជាតិភាគតិច (EAOs) ចំនួន០៧[1] និងគណបក្សនយោបាយឈ្នះឆ្នោតកាលពីឆ្នាំ២០២០ ចំនួន០៧[2] ទៀត។ យើងពុំបានជួបជាមួយនឹងគណបក្សនយោបាយទាំងអស់ ដូចអ្វីដែលយើងបានស្នើទៅ SAC នោះទេ។ គណបក្សដែលមិនបានជួបទាំងនោះមាន០៤ គឺគណបក្សសម្ព័ន្ធជាតិដើម្បីប្រជាធិបតេយ្យ (NLD) គណបក្សសម្ព័ន្ធជាតិសានដើម្បីប្រជាធិបតេយ្យ (Shan National League for Democracy) គណបក្សប្រជាធិបតេយ្យនៃរដ្ឋកាយ៉ា (Kaya State Democracy Party) និងគណបក្សប្រជាជនរដ្ឋកាឈីន (Kachin State People's Party) ដោយគណបក្សទាំងនេះត្រូវបានរកឃើញថា បានធ្វើសកម្មភាពបំពាននឹងច្បាប់របស់មីយ៉ាន់ម៉ា។ រីឯ គណបក្សជាតិវ៉ា (Wa National Party) ពុំអាចចូលរួមប្រជុំបាន ដោយសារមានការលំបាកក្នុងការធ្វើដំណើរ។ ដោយឡែក អង្គការប្រដាប់អាវុធជនជាតិភាគតិចចំនួន០៣ រួម

[1] ១. អង្គការជាតិប៉ាអូ (Pa-O National Organization – PNO) ២. គណបក្សជាតិតាអោង (Ta'ang National Party) ២. គណបក្សអភិវឌ្ឍន៍និងសាមគ្គីភាពសហភាព (Union Solidarity and Development Party – USDP) ៤. សមាជហ្សូមីដើម្បីប្រជាធិបតេយ្យ (Zomi Congress for Democracy) ៥. គណបក្សជាតិអារ៉ាកាន (Arakan National Party) ៦. គណបក្សរណសិរ្សអារ៉ានកាន (Arakan Front Party) ៧. គណបក្សឯកភាពមន (Mon Unity Party)

[2] ១. ក្រុមប្រឹក្សាសន្តិភាពសហភាពជាតិការ៉ែន/កងទ័ពរំដោះជាតិការ៉េន (Karen National Union / Karen National Liberation Army – Peace Council) ហៅកាត់ថា KNC/KNLA-PC) ២. សហភាពប្រជាធិបតេយ្យឡាហ៊ុ (Lahu Democratic Union)
៣. គណបក្សរំដោះអារ៉ាកាន (Arakan Liberation Party – ALP) ៤. កងទ័ពចិត្តករុណារបស់ការ៉ែនប្រជាធិបតេយ្យ (Democratic Karen Benevolent Army – DKBA) ៥. គណបក្សរដ្ឋមនថ្មី (New Mon State Party – NMSP) ៦. អង្គការរំដោះជាតិប៉ាអូ (Pa-O National Liberation Organization – PNLO) ៧. ក្រុមប្រឹក្សាស្តាររដ្ឋស្យាន (Restoration Council of Shan States – RCSS)

មាន សហភាពជាតិការ៉ែន (KNU) រណសិរ្សជាតិឈីន (CNF) និង រណសិរ្សប្រជាធិតេយ្យនិស្សិតភូមា (All Burma Students Democratic Front - ABSDF) ក៏ពុំអាចចូលជួបប្រជុំជាមួយខ្ញុំ និង ក្រុមការងារបាន ដោយមូលហេតុផ្សេងៗគ្នា។

៦. ក្រៅពីនោះ យើងបានជួបជាមួយឯកអគ្គរដ្ឋទូតមួយក្រុម ដែល រួមមានអូស្ត្រាលី សហភាពអឺរ៉ុប បារាំង និងសហរដ្ឋអាមេរិក ព្រមទាំង បានផ្លាស់ប្តូរទស្សនៈលើបញ្ហាជាច្រើនអំពីស្ថានភាពនៅមីយ៉ាន់ម៉ា។ កិច្ចពិភាក្សានេះ មិនមែនមានបំណងចង់ជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង របស់មីយ៉ាន់ម៉ាទេ ប៉ុន្តែគ្រាន់តែដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្តែង នៅនឹងកន្លែង ទៅតាមការមើលឃើញរបស់ទូតទាំងនោះ។

៧. កម្ពុជាក៏ដូចជាអ្នកសង្កេតការណ៍មីយ៉ាន់ម៉ាជាច្រើន នៅតែ ប្រកាន់ជំហរថា លោកស្រី អោង សាន់ស៊ូជី គឺជាតួអង្គដ៏សំខាន់បំផុត មួយក្នុងការជំរុញឱ្យមានកិច្ចសន្ទនាប្រកបដោយបរិយាប័ន្ន និងការ លើកកម្ពស់គោលការណ៍អហិង្សា។ ទោះបីជាយើងបានស្នើសុំជួបជាមួយ លោកស្រី អោង សាន់ស៊ូជី ឬ មេធាវីរបស់លោកស្រី ក៏ដូចជាលោកស្រី ស៊ូ ស៊ូ ល្វីន ភរិយាអតីតប្រធានាធិបតីរបស់មីយ៉ាន់ម៉ាម្តងហើយម្តង ទៀតក៏ដោយ ក៏យើងនៅតែពុំអាចជួបបាន។ គេបានប្រាប់យើងថា លោកស្រី អោង សាន់ស៊ូជី កំពុងស្ថិតក្រោមនីតិវិធីតុលាការ ហើយ ចំពោះលោកស្រី ស៊ូ ស៊ូ ល្វីន គេបានប្រាប់យើងថា គាត់មានបញ្ហា សុខភាព។

## II. តើយើងបានពិភាក្សាពីអ្វីខ្លះ?

៨. ខ្ញុំសូមរៀបរាប់ខ្លឹមសារនៃកិច្ចពិភាក្សាដោយផ្អែកលើអាទិភាពចំនួនបីនៃការងាររបស់យើង គឺ (១) ការកាត់បន្ថយ/ការបញ្ឈប់អំពើហិង្សា (២) ការផ្តល់ជំនួយមនុស្សធម៌ដល់ប្រជាជនដែលត្រូវការបំផុតដោយឈរលើគោលការណ៍មិនលម្អៀង និង (៣) ការជំរុញឱ្យមានបរិយាកាសអំណោយផល សម្រាប់កិច្ចសន្ទនាប្រកបដោយសន្តិវិធី និងបរិយាប័ន្ន។

### ក. ការកាត់បន្ថយ/ការបញ្ឈប់អំពើហិង្សា

៩. ខ្ញុំបានរំលឹកឡើងវិញនូវកិច្ចសន្ទនារវាង សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និង ឯកឧត្តមនាយឧត្តមសេនីយ៍ មីន អោងឡាំង ស្តីពីកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការបញ្ឈប់អំពើហិង្សា និងសំណើរបស់ សម្តេចតេជោ ឱ្យគ្រប់ភាគីទាំងអស់ប្រកាន់ខ្ជាប់នូវភាពអត់ធ្មត់ជាអតិបរមា។ តាមរយៈការពិភាក្សាអស់រយៈពេលយ៉ាងយូររវាងខ្ញុំ ជាមួយឯកឧត្តមនាយឧត្តមសេនីយ៍ មីន អោងឡាំង (ជាងពីរម៉ោង) និងការសន្ទនាដោយឡែកជាមួយឧត្តមសេនីយ៍ឯក យ៉ា ពៀ យើងគួរតែអាចវាយតម្លៃបានថា ក្រុមប្រដាប់អាវុធផ្សេងៗទៀតក៏មានចំណែកទទួលខុសត្រូវក្នុងការបង្កអំពើហិង្សា ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ការសម្លាប់មន្ត្រីរាជការ គ្រូបង្រៀន និងបុគ្គលិកសុខាភិបាល ដែលស្ម័គ្រចិត្តបន្តការងារឡើងវិញ ក្នុងអំឡុងពេលនៃវិបត្តិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខាភិបាលរបស់ប្រជាជន និងការសិក្សារបស់កុមារ។

១០. ដំណើរការនៃការបញ្ចប់អំពើហិង្សា អាចសម្រេចទៅបានលុះត្រាតែមានការចូលរួម និងភាពអត់ធ្មត់ខ្ពស់ពីភាគីទាំងអស់ និងប្រកបដោយមានឆន្ទៈស្មោះស។ អង្គការប្រដាប់អាវុធជនជាតិភាគតិច (EAOs) និងគណបក្សនយោបាយទាំងអស់ ដែលយើងបានជួបសុទ្ធតែបានសម្តែងការព្រួយបារម្ភចំពោះអំពើហិង្សា ការគំរាមកំហែង និងការបំភិតបំភ័យនានាដែលកំពុងបន្តកើតមានលើជនស៊ីវិល នៅក្នុងតំបន់ដែលពួកគេគ្រប់គ្រង។

១១. អំពើហិង្សាទាំងនោះកើតមានឡើងក្រោមទិដ្ឋភាព ២យ៉ាង។ ទី១ គឺអំពើហិង្សាដែលបង្កឡើងដោយការប្រយុទ្ធគ្នាជាយូរមកហើយរវាងកងកម្លាំងយោធា និងកងកម្លាំងរបស់អង្គការប្រដាប់អាវុធជនជាតិភាគតិច។ ទី២ គឺការប៉ះទង្គិចប្រដាប់អាវុធជាញឹកញាប់ និងធ្ងន់ធ្ងររវាងកងកម្លាំងយោធា និងកងកម្លាំងប្រជាការពារ (PDF) ដែលបានកើតឡើងក្រោយខែកុម្ភៈ ឆ្នាំ២០២១។

១២. ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ (SAC) បានបង្ហាញនូវរបាយការណ៍ស្តីពីអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងដោយកងកម្លាំងប្រដាប់អាវុធផ្សេងៗ ដូចជាការកាត់ក្បាល និងការកាត់អវយវៈ។ អំពើឃាតកម្ម ការបំផ្ទុះគ្រាប់បែក និងការធ្វើឃាត បានបង្កើតឱ្យមានជាវដ្តនៃការសងសឹក និងគំរាមកំហែងវិលទៅវិលមកមិនចេះចប់ ដែលសកម្មភាពទាំងអស់នេះបានរំខានដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនមីយ៉ាន់ម៉ា ព្រមទាំងបានកាត់ផ្តាច់ហេដ្ឋរចនាសម្ព័ន្ធចាំបាច់ជាមូលដ្ឋានសម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាសេវាសាធារណៈ។ យើងក៏បានទទួលព័ត៌មានពីករណីដុតភូមិ និងការបង្អាក់រំខានដល់ការដឹកជញ្ជូន

ជំនួយមនុស្សធម៌ផងដែរ។ វដ្តនៃការសងសឹកគ្មានទីបញ្ចប់នេះ អាចរុញច្រានមីយ៉ាន់ម៉ាឱ្យធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិលទូទាំងប្រទេសបាន។

១៣. ខ្ញុំបានរំលឹកឡើងវិញនូវការអំពាវនាវរបស់ សម្តេចតេជោ ដែលស្នើឱ្យក្រុមប្រឹក្សារដ្ឋបាលរដ្ឋ (SAC) អនុវត្តនូវការអត់ធ្មត់ជាអតិបរមា និងជៀសវាងឱ្យបាននូវការតបតណាមួយដែលមិនសមាមាត្រ។ ខ្ញុំក៏បានជំរុញឱ្យអង្គការប្រដាប់អាវុធជនជាតិភាគតិច (EAOs) និងគណបក្សនយោបាយទាំងអស់ប្រកាន់ខ្ជាប់នូវគោលការណ៍អហិង្សា។ អង្គការប្រដាប់អាវុធជនជាតិភាគតិច (EAOs) និងគណបក្សនយោបាយដែលយើងបានជួប បានធានាអះអាងថា ពួកគេប្រឆាំងជាដាច់ខាតនឹងអំពើហិង្សាគ្រប់ទម្រង់ និងគ្រប់រូបភាព។ ពិតណាស់ថា ភាគីទាំងឡាយដែលមានសមត្ថភាព និងលទ្ធភាពបង្កការគំរាមកំហែង មិនត្រឹមតែធ្វើការសន្យាប៉ុណ្ណោះទេ តែត្រូវធ្វើសកម្មភាពជាក់ស្តែងទៀតផង។ ពួកគេត្រូវតែបញ្ឈប់ការប្រយុទ្ធ។

១៤. អ្វីដែលជាសញ្ញាវិជ្ជមាននោះគឺថា ការបន្តជំរុញកិច្ចព្រមព្រៀងបទឈប់បាញ់ថ្នាក់ជាតិ (NCA) បានធ្វើឱ្យមីយ៉ាន់ម៉ាទទួលបានស្ថិរភាពមួយកម្រិត ហើយខ្ញុំក៏បានស្វាគមន៍ការប្រកាសរបស់ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ ក្នុងការកំណត់យកឆ្នាំ ២០២២ ជាឆ្នាំនៃសន្តិភាព។ ឯកឧត្តមនាយឧត្តមសេនីយ៍ មីន អោងឡាំង បានចែករំលែកជាមួយយើងខ្ញុំ អំពីកិច្ចខិតខំប្រឹងប្រែងរបស់គាត់ ដើម្បីសម្រេចឱ្យបាននូវកិច្ចព្រមព្រៀងបទឈប់បាញ់ថ្នាក់ជាតិនេះ តាមរយៈការជួបដោយផ្ទាល់ជាមួយអង្គការប្រដាប់អាវុធជនជាតិភាគតិច (EAOs) ចំនួន០៨ ហើយនឹងបន្តជួបជាមួយនឹង EAOs ផ្សេងទៀតនាពេលឆាប់ៗនេះ។ ខ្ញុំក៏ត្រេកអរផង

ដែរដែលបានទទួលដំណឹងថា កុមារនៅមីយ៉ាន់ម៉ាអាចចាប់ផ្តើមការសិក្សារបស់ពួកគេឡើងវិញ។ កុមារទាំងនោះជាអនាគតរបស់ប្រទេសជាតិ ហើយការទទួលបានការអប់រំរបស់ពួកគេគួរតែជាកាតព្វកិច្ចរបស់គ្រប់ភាគីទាំងអស់នៃជម្លោះ។ គណបក្សនយោបាយមួយចំនួនក៏បានជូនដំណឹងអំពីសកម្មភាពមនុស្សធម៌ របស់ពួកគេក្នុងការទទួលយកជនបំលាស់ទីក្នុងស្រុក (IDPs) ពីតំបន់ផ្សេងទៀត ចូលមកក្នុងតំបន់ដែលខ្លួនគ្រប់គ្រង។ ខ្ញុំរំជួលចិត្តណាស់នៅពេលបានដឹងថា មនោសញ្ចេតនាមនុស្សធម៌នៅតែកើតមាន បើទោះជាស្ថិតនៅក្នុងបរិយាកាសអកុសលនៃអំពើហិង្សាក៏ដោយ។

១៥. ចំពោះបញ្ហានេះ ខ្ញុំបានចែករំលែកជាមួយអន្តរការីរបស់ខ្ញុំទាំងអស់ អំពីតម្លៃនៃសន្តិភាពដែលមិនអាចកាត់ថ្លៃបាន និងមេរៀនដែលកម្ពុជាឆ្លងកាត់ ដើម្បីបញ្ចប់សង្គ្រាមរ៉ាំរ៉ៃក្នុងស្រុក តាមរយៈគោលនយោបាយឈ្នះ-ឈ្នះ ដែលផ្តួចផ្តើមឡើងដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន**។ យើងមានអារម្មណ៍ថា ទាល់តែសន្តិភាពត្រូវបានបាត់បង់ ទើបមនុស្សយើងឱ្យតម្លៃសន្តិភាព។

## ខ- ការផ្តល់ជំនួយមនុស្សធម៌

១៦. ការងារអាទិភាពមួយនេះគឺជាការងារដែលទទួលបានវឌ្ឍនភាពជាក់ស្តែងច្រើនជាងគេបំផុត។ មូលហេតុគឺងាយយល់ទេ៖ ការងារនេះគឺការងារមិនមែននយោបាយ ឬជាប់ពណ៌នយោបាយតិចតួចប៉ុណ្ណោះ។ យើងបានចូលរួមជាសាក្សីក្នុងការផ្តល់ជំនួយជាវ៉ាក់សាំងចំនួន ២លានដូស ពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនទៅកាន់មីយ៉ាន់ម៉ា

តាមរយៈក្របខ័ណ្ឌដែលដឹកនាំដោយអាស៊ាន។ ឆ្លៀតឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសុខាភិបាលមីយ៉ាន់ម៉ា ក្នុងការគ្រប់គ្រងការចាក់វ៉ាក់សាំងជូនប្រជាជន ដែលសម្រេចបានក្នុងទំហំដ៏ធំធេង ទោះបីស្ថិតក្នុងកាលៈទេសៈដ៏លំបាកនេះក៏ដោយ។ ពិតណាស់ថា នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ហើយយើងនឹងខិតខំក្នុងការនាំយកវ៉ាក់សាំងបន្ថែមទៀត ទៅដល់ដៃរបស់ប្រជាជន។

១៧. ខ្ញុំសូមរំលឹកថា នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់កាលពីដើមខែឧសភា នៅភ្នំពេញ កម្ពុជាបានផ្តួចផ្តើមកម្មវិធីចាក់វ៉ាក់សាំងរួមគ្នាបន្ថែមពីលើការផ្តល់ជំនួយមនុស្សធម៌ ហើយយើងពិតជារីករាយណាស់ដែលគំនិតផ្តួចផ្តើមនេះ ទទួលបានការគាំទ្រយ៉ាងមុតមាំពីដៃគូសន្ទនារបស់អាស៊ាន។ ក្នុងពិធីប្រគល់វ៉ាក់សាំងនេះ ខ្ញុំបានគូសបញ្ជាក់ថា "**ជំនួយមនុស្សធម៌ ពុំគួរត្រូវបានលាបពណ៌អ្វីឡើយ**" ហើយភាគីទាំងអស់គួរតែទុកមួយឡែកនូវការខ្វែងគំនិតគ្នាផ្នែកនយោបាយ ដើម្បីយើងអាចបោះជំហានដំបូងទៅមុខ ក្នុងការផ្តល់ជំនួយមនុស្សធម៌ទៅដល់ប្រជាជនដែលកំពុងត្រូវការ។

១៨. នៅក្នុងកិច្ចប្រជុំជាមួយក្រុមការងារចំពោះកិច្ចរបស់មីយ៉ាន់ម៉ាទទួលបន្ទុកការងារជំនួយមនុស្សធម៌អាស៊ាន យើងបានពិភាក្សាអំពីវិធីសាស្ត្រដែលទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អាចចូលរួមក្នុងការងារមនុស្សធម៌ដែលដឹកនាំដោយអាស៊ាន ដោយមានកិច្ចសហប្រតិបត្តិការ និងការ

សម្របសម្រួលពីមីយ៉ាន់ម៉ា។ យើងបានលើកសំណើទៅក្រុមការងារចំពោះកិច្ចមីយ៉ាន់ម៉ា ឱ្យជួយសម្របសម្រួល និងធ្វើឱ្យសាមញ្ញនីតិវិធី ហើយភាគីមីយ៉ាន់ម៉ាក៏បានអំពាវនាវឱ្យអង្គការអន្តរជាតិ និងដៃគូនានាបង្កើននូវកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយអាជ្ញាធរមូលដ្ឋាន និងជៀសវាងការដាក់គម្លាតនយោបាយ (political distancing)។

១៩. ខ្ញុំក៏បានគូសបញ្ជាក់ផងដែរថា យើងត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីគាំទ្រដល់មជ្ឈមណ្ឌលសម្របសម្រួលជំនួយមនុស្សធម៌អាស៊ាន (មជ្ឈមណ្ឌល AHA) ក្នុងការបញ្ចប់ការវាយតម្លៃតម្រូវការរួម (JNA) ឱ្យបានឆាប់បំផុត ព្រោះលទ្ធផលដែលបានមកពីការវាយតម្លៃនេះនឹងអាចឱ្យអាស៊ានអាចចាប់ផ្តើមប្រតិបត្តិការផ្តល់ជំនួយមនុស្សធម៌ដំណាក់កាលទី២ជូនទៅដល់មីយ៉ាន់ម៉ាបាន។ លើសពីនេះ ខ្ញុំពិតជារីករាយដែលបានឃើញ ក្រុមការងារចំពោះកិច្ចមីយ៉ាន់ម៉ាបង្ហាញនូវឆន្ទៈក្នុងការអនុញ្ញាតឱ្យការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការសម្របសម្រួលកិច្ចការមនុស្សធម៌ (UN OCHA) និងអង្គការស្បៀងអាហារពិភពលោក (WFP) ចូលរួមក្នុងប្រតិបត្តិការវាយតម្លៃតម្រូវការរួម (JNA) ជាមួយមជ្ឈមណ្ឌល AHA ក្នុងនាមជាអ្នកសង្កេតការណ៍។

២០. ខ្ញុំក៏បានពាំនាំនូវឆន្ទៈសប្បុរសរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលមានបំណងបញ្ជូនបុគ្គលិកសុខាភិបាលស្ម័គ្រចិត្តរបស់កម្ពុជា ទៅមីយ៉ាន់ម៉ា ដើម្បីចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងនៅមីយ៉ាន់ម៉ា ហើយក្រុមការងារចំពោះកិច្ចមីយ៉ាន់ម៉ាបានបង្ហាញនូវការ

ស្វាគមន៍យ៉ាងកក់ក្តៅចំពោះកាយវិការសុឆន្ទៈនេះ។ យើងនឹងពិភាក្សាលម្អិតទៅលើគំនិតផ្តួចផ្តើមនេះ ជាមួយនឹងលេខាធិការដ្ឋានអាស៊ាន មជ្ឈមណ្ឌល AHA និងភាគីពាក់ព័ន្ធផ្សេងទៀតនៅមីយ៉ាន់ម៉ា នៅពេលក្រោយ។

២១. ក្នុងគោលដៅពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការទូលំទូលាយ ខ្ញុំបានជំរុញឱ្យក្រុមប្រឹក្សារដ្ឋបាលរដ្ឋស្វែងរកវិធីសាស្ត្រធ្វើការជាមួយប្រេសិតពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោកស្រី Noeleen Heyzer ដើម្បីយើងអាចពង្រឹងបន្ថែមទៀតនូវសហថាមភាពរវាងអាស៊ាន និងអង្គការសហប្រជាជាតិ ដូចដែលបានព្រមព្រៀងដោយរដ្ឋមន្ត្រីការបរទេសអាស៊ានក្នុងឱកាសនៃកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន កាលពីខែកុម្ភៈ កន្លងទៅ។

២២. ខ្ញុំសូមបន្តទៅការងារអាទិភាពទី៣ ។

## គ- ការជំរុញឱ្យមានបរិយាកាសអំណោយផល សម្រាប់ការសន្ទនាប្រកបដោយសន្តិភាព និងបរិយាប័ន្ន

២៣. នេះគឺជាបញ្ហាដែលពិបាកដោះស្រាយបំផុត។ ជម្លោះនៅមីយ៉ាន់ម៉ាបានចាក់ឫសយ៉ាងជ្រៅក្នុងប្រវត្តិសាស្ត្រជាង៧ទសវត្សរ៍មកហើយ។ ជម្លោះនេះមានទិដ្ឋភាពច្រើនយ៉ាង តាំងពីទិដ្ឋភាពនយោបាយ ការបែងចែកអំណាច ដល់ទិដ្ឋភាពប្រវត្តិសាស្ត្រ វប្បធម៌ និងអត្តសញ្ញាណ។

២៤. នៅពេលជួបជាមួយក្រុម EAOs និងគណបក្សនយោបាយ ពួកគេស្ទើរតែទាំងអស់សុទ្ធតែបានស្នើសុំឱ្យប្រេសិតពិសេស ជួយស្វែង

រកដំណោះស្រាយនយោបាយចំពោះវិបត្តិដ៏យូរអង្វែងនេះ។ ពិតណាស់ថា ខ្ញុំទទួលបានការលើកទឹកចិត្តតាមរយៈសំណើដ៏ស្មោះត្រង់មួយនេះ ប៉ុន្តែ យ៉ាងណាក្តី ខ្ញុំត្រូវទទួលស្គាល់ថា ការរំពឹងបែបនេះ គឺជាសេចក្តីរំពឹងហួសពីព្រំដែនកំណត់នៃអាណត្តិរបស់ប្រេសិតពិសេស។ ខ្ញុំបានប្រាប់អង្គការប្រដាប់អាវុធជនជាតិភាគតិច (EAOs) ទាំងនោះថា អាស៊ានគ្រាន់តែជាអ្នកសម្របសម្រួលប៉ុណ្ណោះ និងមិនមែនជាភាគីពាក់ព័ន្ធផ្ទាល់នៅក្នុងជម្លោះនៅមីយ៉ាន់ម៉ាឡើយ ហើយជម្លោះនេះគឺមានតែមីយ៉ាន់ម៉ាខ្លួនឯងទេ ដែលអាចដោះស្រាយបានតាមរយៈយន្តការដែលជារបស់មីយ៉ាន់ម៉ា និងដឹកនាំដោយមីយ៉ាន់ម៉ា។

២៥. ខ្ញុំនៅសល់អាណត្តិប្រមាណតែ៦ខែទៀតប៉ុណ្ណោះ ក្នុងនាមជាប្រេសិតពិសេស ដូច្នេះ ខ្ញុំគួរតែនិយាយថា ខ្ញុំពុំមានឱសថទិព្វ ឬវេទមន្តអ្វី ដើម្បីដោះស្រាយវិបត្តិនៅមីយ៉ាន់ម៉ានោះឡើយ។

២៦. និយាយដោយការពិតជាក់ស្តែង អ្វីដែលអាស៊ាន និងខ្លួនខ្ញុំអាចធ្វើបានគឺជួយសម្រួលដល់ដំណើរការសន្តិភាព និងកិច្ចសន្ទនាមួយដែលមានបរិយាប័ន្ន និងអាចទទួលយកបានពីគ្រប់ភាគីទាំងអស់។ អ្វីដែលយើងអាចធ្វើបាន គឺជួយបញ្ឈប់អំពើហិង្សា និងរំលឹកដល់ភាគីពាក់ព័ន្ធទាំងអស់ កុំឱ្យរុញច្រានប្រទេសនេះឱ្យធ្លាក់ក្នុងសង្គ្រាមស៊ីវិលពេញលេញ ដែលអាចបង្កឱ្យមានអស្ថិរភាព និងអសន្តិសុខទូទាំងតំបន់ និងបង្កនូវសោកនាដកម្មកាន់តែខ្លាំងឡើងដល់ប្រជាជនមីយ៉ាន់ម៉ា។

២៧. តាំងពីឆ្នាំមុនមក យើងទាំងអស់គ្នាតែងចោទជាសំណួរថា **តើអ្វីទៅដែលអាចជាច្រកចេញពីវិបត្តិនយោបាយនៅមីយ៉ាន់ម៉ាបច្ចុប្បន្ន?**

២៨. ក្នុងនាមខ្ញុំជាប្រេសិតពិសេស ខ្ញុំបានខិតខំស្វែងយល់ និងស្តាប់រាល់មតិយោបល់ទាំងអស់ពីមជ្ឈដ្ឋានខាងក្នុង និងក្រៅមីយ៉ាន់ម៉ា។ គ្រប់គ្នាបានសម្តែងចេតនាចង់បញ្ចប់ជម្លោះបច្ចុប្បន្ន និងនាំមកនូវសន្តិភាពយូរអង្វែងជូនប្រទេសនេះឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។

២៩. ផែនទីបង្ហាញផ្លូវ៥ចំណុច (5 RM) របស់ SAC បានកំណត់យកការរៀបចំការបោះឆ្នោតសកលនៅឆ្នាំ២០២៣ ជាច្រកចេញដើម្បីនាំមីយ៉ាន់ម៉ាត្រលប់ទៅរកប្រក្រតីភាពឡើងវិញ ដោយបានសន្យាផ្ទេរអំណាចទៅឱ្យអ្នកដែលទទួលបានជ័យជំនះនៅក្នុងការបោះឆ្នោតនោះ។ កិច្ចព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុចរបស់ថ្នាក់ដឹកនាំអាស៊ាន មិនបាននិយាយអ្វីអំពីការបោះឆ្នោតនោះឡើយ ដូច្នេះហើយ ប្រេសិតពិសេសពុំមានអាណត្តិទាក់ទងនឹងការបោះឆ្នោតដែរ។

៣០. តាមរយៈការពិភាក្សារបស់យើង នៅមុនពេល និងអំឡុងពេលនៃទស្សនកិច្ចនេះ យើងបានស្តាប់ឮមតិរបស់ប្រជាជន និងដៃគូខាងក្រៅ ដែលប្រឆាំងនឹងការស្នើរៀបចំការបោះឆ្នោតនៅឆ្នាំ២០២៣ ហើយអ្នកទាំងនោះ ក៏បានអំពាវនាវឱ្យប្រគល់អំណាចទៅឱ្យរដ្ឋាភិបាលដែលកើតចេញពីលទ្ធផលនៃការបោះឆ្នោតឆ្នាំ២០២០ឡើងវិញ។

៣១. ដោយឡែក បើមើលទៅជ្រុងម្ខាងទៀត យើងក៏បានឮពីការព្រួយបារម្ភថា ការចង់បានបែបនេះនឹងជំរុញឱ្យមានការជាប់គាំង និងបន្តអូសបន្លាយស្ថានភាពអសន្តិសុខបច្ចុប្បន្ន។ អង្គការប្រដាប់អាវុធជនជាតិភាគតិច (EAOs) ដែលយើងបានជួបនៅទីក្រុងណៃពិដោ និងគណបក្សនយោបាយ ដែលបានជួបនៅក្រុងយ៉ាងហ្គូន បានសម្តែង

នូវការគាំទ្រចំពោះការបោះឆ្នោតសកលនេះ ប្រសិនបើមានបរិយាប័ន្ន និងអាចទទួលយកបាន។

៣២. ក្រុមប្រឹក្សារដ្ឋបាលរដ្ឋបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការរៀបចំការបោះឆ្នោត និងបានប្តេជ្ញាថា ការបោះឆ្នោតនេះនឹងប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌។ ប្រទេសមួយចំនួនបានសម្តែងនូវការគាំទ្រចំពោះការបោះឆ្នោតនេះ ដោយភាពស្ងៀមស្ងាត់ ដោយសារពួកគេបារម្ភពីប្រតិកម្មតប និងការរិះគន់ពីសំណាក់សាធារណជនថា ជម្រើសនេះនឹងផ្តល់ភាពស្របច្បាប់ដល់ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ ហើយថាការបោះឆ្នោតណាមួយដែលរៀបចំដោយក្រុមប្រឹក្សារដ្ឋបាលរដ្ឋ នឹងមិនមានបរិយាប័ន្ន សេរី យុត្តិធម៌ និងអាចទុកចិត្តនោះទេ។

៣៣. សំណួរគឺនៅត្រង់ថា តើយើងមានជម្រើសដោយសន្តិវិធីណាមួយផ្សេងក្រៅពីការបោះឆ្នោតដែរឬទេ? ប្រសិនបើការបោះឆ្នោតអាចក្លាយជាជម្រើស និងជាច្រកចេញដោយសន្តិវិធីតែមួយគត់ពីវិបត្តិនយោបាយបច្ចុប្បន្ន តើយើងត្រូវធ្វើដូចម្តេចដើម្បីឱ្យការបោះឆ្នោតនោះមានបរិយាប័ន្ន សេរី និងយុត្តិធម៌?

៣៤. ចំណុចគួរចាប់អារម្មណ៍មួយទៀតដែលខ្ញុំបានឮគឺថា ភាគីពាក់ព័ន្ធជាច្រើនបានលើកទស្សនៈថា រដ្ឋធម្មនុញ្ញឆ្នាំ២០០៨ មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការដោះស្រាយវិបត្តិបច្ចុប្បន្ននោះទេ ហើយក៏បានលើកឡើងថា រដ្ឋធម្មនុញ្ញឆ្នាំ២០០៨នេះ គឺជាដើមហេតុមួយនៃវិបត្តិនយោបាយរយៈពេលវែងរបស់មីយ៉ាន់ម៉ា ហើយមានការចាំបាច់ដែលត្រូវធ្វើវិសោធនកម្ម ឬក៏តាក់តែងរដ្ឋធម្មនុញ្ញថ្មីតែម្តង។

៣៥. ភារកិច្ចទាំងនេះគឺមានវិសាលភាពធំធេងណាស់។ ជាថ្មីម្តងទៀត ខ្ញុំសូមសង្កត់ធ្ងន់ថា ចំពោះការសម្រេចចិត្តថា «តើត្រូវមានការបោះឆ្នោតឬក៏អត់?» ឬ «គួរធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលមានស្រាប់ ឬក៏តាក់តែងរដ្ឋធម្មនុញ្ញថ្មី?» ទាំងអស់នេះសុទ្ធតែជាសំណួរដែលទាក់ទងទៅនឹងជោគវាសនារបស់មីយ៉ាន់ម៉ា ដែលត្រូវតែសម្រេចដោយភាគីពាក់ព័ន្ធទាំងអស់នៅមីយ៉ាន់ម៉ាផ្ទាល់។ មជ្ឈដ្ឋានខាងក្រៅគឺអាចត្រឹមតែចែករំលែកទស្សនៈ មតិយោបល់ និងអនុសាសន៍ តែប៉ុណ្ណោះ។

៣៦. ប្រសិនបើយើងយកករណីរបស់កម្ពុជា ធ្វើជាករណីសិក្សា យើងអាចដឹងបានថា កិច្ចសន្ទនាសន្តិភាពត្រូវការពេលវេលា ភាពអំណត់ និងសម្បទានពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ដោយសារភាគីពាក់ព័ន្ធទាំងអស់មានផលប្រយោជន៍ផ្សេងៗគ្នា ដូច្នេះ កិច្ចសន្ទនាសន្តិភាព នេះប្រៀបបាននឹងដំណើរការចរចាតថ្លៃមួយដែលមានរយៈពេលយូរ។ កម្ពុជាត្រូវការរយៈពេល ២០ឆ្នាំ ដើម្បីទទួលបានសន្តិភាពពេញលេញ។ ក្រោយរំដោះខ្លួនចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមបាន៨ឆ្នាំ ទើបកម្ពុជាអាចចាប់ផ្តើមរៀបចំកិច្ចចរចាស្វែងរកសន្តិភាពលើកដំបូងបាន ហើយយើងក៏ត្រូវចំណាយពេល៤ឆ្នាំ នៅក្នុងដំណើរការចរចាដ៏ស្មុគស្មាញ មុនពេលភាគីទាំងអស់អាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបាន។ ការបោះឆ្នោតត្រូវបានរៀបចំនៅ២ឆ្នាំបន្ទាប់ និងបានបើកផ្លូវឱ្យមានការរៀបចំសភាធម្មនុញ្ញដើម្បីតាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញថ្មី។ យ៉ាងណាមិញ សន្តិភាពពេលនោះនៅមិនទាន់មានលក្ខណៈពេញលេញនៅឡើយទេ ដោយសារ

តែក្រុមខ្មែរក្រហមបានធ្វើពហិការដំណើរការសន្តិភាព ហើយក៏នៅតែបន្តគ្រប់គ្រងទឹកដីមួយផ្នែកនៃប្រទេសកម្ពុជា។ យើងត្រូវចំណាយពេលអស់ ៥ឆ្នាំទៀត ទៅលើការប្រយុទ្ធផង និងការចរចាផង មុនពេលដែលយើង អាចទទួលបាននូវសន្តិភាព និងឯកភាពជាតិពេញលេញតាមរយៈគោលនយោបាយឈ្នះ-ឈ្នះ។

៣៧. ទាំងអស់នេះគឺជាជំហានដែលកម្ពុជាបានឆ្លងកាត់នាពេលកន្លងមក។ មិនមានផ្លូវកាត់នោះទេ ហើយក៏មិនមានដំណើការមួយដែលល្អឥតខ្ចោះនោះដែរ។ ក្នុងការអំពាវនាវឱ្យមានកិច្ចសន្ទនាប្រកបដោយបរិយាប័ន្ន ខ្ញុំបានចែករំលែកថា ការចាត់ទុកគ្នាទៅវិញទៅមកថាជាក្រុម ឬអង្គការភេរវកម្ម មិនអាចបង្កើតឱ្យមានកិច្ចសន្ទនាប្រកបដោយសន្តិវិធី និងបរិយាប័ន្នបាននោះទេ។ ខ្ញុំបានជំរុញឱ្យមានការបើកចំហទ្វារសម្រាប់ការចូលរួមក្នុងដំណើរការសន្តិភាព ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ បើទោះបីពួកគេមានការកំណត់ថ្នាក់ ឬប្រភេទបែបណាក៏ដោយ។ ខ្ញុំមានការលើកទឹកចិត្ត នៅពេលដែលបានដឹងថាក្រុមប្រឹក្សារដ្ឋបាលរដ្ឋ បានបើកទ្វារចំហសម្រាប់កិច្ចសន្ទនានេះ ជាពិសេសសម្រាប់អ្នកដែលត្រូវបានចាត់ថ្នាក់ថាជាក្រុមភេរវករ បើទោះបីមានភ្ជាប់នូវល័ក្ខខ័ណ្ឌមួយចំនួនក៏ដោយចុះ។

## ការសន្និដ្ឋាន៖ តើខ្ញុំវាយតម្លៃលើលទ្ធផលនៃទស្សនកិច្ចនេះយ៉ាងដូចម្តេច?

៣៨. និយាយឱ្យសាមញ្ញ លទ្ធផលនៃទស្សនកិច្ចគឺមានវឌ្ឍនភាពវិជ្ជមានមួយចំនួន។ ខ្ញុំមានសុទិដ្ឋិនិយម ដោយហ៊ានអះអាងថា យើងសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ខ្លះៗដែរ។

(១) យើងបានជួបអ្នកពាក់ព័ន្ធច្រើនជាង និងបានលើកប្រធានបទច្រើនជាង មកពិភាក្សា បានបើកច្រកថ្មីសម្រាប់ឈានដល់ការចរចានយោបាយ។ ត្រង់ចំណុចនេះ គួរបញ្ជាក់ថែមទៀតថា មុននេះមិនមានទាល់តែសោះនូវលទ្ធភាពចរចាជាមួយបុគ្គល ឬក៏ក្រុមទាំងឡាយណាដែរ ក្រុមប្រឹក្សារដ្ឋបាលរដ្ឋចាត់ទុកថាជាភេរវករ។ នៅពេលដែលយើងលើកសំនួរ ជាពិសេសជាមួយនឹងឧត្តមសេនីយ៍ឯក យ៉ា ពៀ ដែលគាត់ជាអ្នកទទួលបន្ទុកនៃកិច្ចចរចាសន្តិភាពនេះ យើងបានលើកសំនួរថា ប្រសិនបើមានបុគ្គល ឬក្រុមណាមួយដែលក្រុមប្រឹក្សារដ្ឋបាលរដ្ឋចាត់ទុកថាជាភេរវករ ហើយបុគ្គល ឬក្រុមនោះចង់បោះបង់ការប្រយុទ្ធ ហើយមកចូលរួមចរចាជាមួយនឹងក្រុមប្រឹក្សារដ្ឋបាលរដ្ឋ តើអ្នកយល់យ៉ាងដូចម្ដេច? ខ្ញុំបានបន្ថែមទៀតថា ក្នុងករណីដែលប្រកាន់ជំហរបច្ចុប្បន្ន ដែលបដិសេធដាច់ខាត មិនចរចាមិននិយាយជាមួយនឹងក្រុមទាំងឡាយណាដែលក្រុងណៃពិដោចាត់ទុកថាជាភេរវករ នោះ ការធ្វើបែបនេះ នឹងបន្តឱ្យមានការប្រយុទ្ធគ្នាមិនចេះចប់។ បើយើងមិនព្រមចរចាជាមួយនឹងគាត់នៅពេលដែលគាត់បានបោះបង់ការប្រយុទ្ធហើយ គឺគាត់អត់មានជម្រើសអ្វីផ្សេងក្រៅពីត្រឡប់ទៅកាន់កាំភ្លើងដើម្បីប្រយុទ្ធនោះទេ។ យើងបានទទួលចម្លើយជាការលើកទឹកចិត្តផងដែរ គឺថាអ្នកទាំងនោះ ពោលគឺអ្នកដែលចាត់រួចទៅហើយថាជាភេរវករ គឺអាចចូលរួមចរចាបាន តែអ្នកទាំងនោះត្រូវផ្លាស់ប្ដូរផ្នត់គំនិត (Mindset) របស់ខ្លួន ហើយលក្ខខ័ណ្ឌនោះគឺមាន ០៣យ៉ាង៖ ទី១ មិនមានបំណងបំផ្លាញរដ្ឋាភិបាល ទី២ មិនមានបំណងមកជំនួសរដ្ឋាភិបាល និងទី៣ យករដ្ឋ

ធម្មនុញ្ញឆ្នាំ២០០៨ ធ្វើជាមូលដ្ឋានចរចាសន្តិភាព។ បើទោះបីជាមានលក្ខខណ្ឌយ៉ាងនេះក៏ដោយ ខ្ញុំយល់ថា យ៉ាងហោចណាស់ ក៏យើងបានបើកផ្លូវឱ្យមានលទ្ធភាពនៅក្នុងការចរចាជាមួយគ្នាដែរ មានន័យថា យើងអាចធ្វើឱ្យកង់នៃការចរចាសន្តិភាពនេះ អាចវិលទៅមុខបាន។ ឯលក្ខខណ្ឌយ៉ាងណានោះ គឺអាស្រ័យលើភាគីពាក់ព័ន្ធក្នុងប្រទេសមីយ៉ាន់ម៉ាដោះស្រាយជាមួយគ្នាចុះ។ យ៉ាងហោចណាស់ ទ្វារនេះក៏បានបង្ហើបហើយ ហើយចូលបានប៉ុន្មាន ចង់ចូលឬមិនចូលយ៉ាងណាមិញ គឺអាស្រ័យទៅលើមីយ៉ាន់ម៉ាខ្លួនឯង។ ដូចដែលនិយាយពីដើមរួចមកហើយ ថាដំណើរការចរចាសន្តិភាពនេះគឺជាដំណើរការមួយដែលគ្រប់គ្រង និងដឹកនាំផ្ទាល់ដោយមីយ៉ាន់ម៉ាខ្លួនឯង។

(២) យើងបានបន្តរុញការងារផ្តល់ជំនួយមនុស្សធម៌ឈានទៅមុខដោយបន្តដោះស្រាយការលំបាក និងរកចំណុចត្រូវរួតរួតគ្នាបន្ថែម។

(៣) យើងប្រមូលសម្លេងគាំទ្រក្នុងការឈប់បាញ់គ្នា ការការពារជនស៊ីវិល និងតម្រូវការនៃការដោះស្រាយដោយនយោបាយនូវវិបត្តិបច្ចុប្បន្ន។ អង្គការប្រដាប់អាវុធជនជាតិភាគតិច និងគណបក្សនយោបាយដែលយើងបានជួប សុទ្ធតែសម្តែងនូវឆន្ទៈចង់ឈានទៅរកសន្តិភាពឱ្យបានឆាប់ ហើយគិតគូរអំពីការការពារអាយុជីវិតរបស់ជនស៊ីវិល និងផ្តោតការយកចិត្តទុកដាក់ទៅលើការកសាងប្រទេសជាតិឡើងវិញ។

យើងខ្ញុំបាននិងកំពុងប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីជំរុញឱ្យមានភាពជឿនលឿនបន្ថែមទៀតចំពោះការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆ័ន្ទ៥ចំណុច។

៣៩. ខ្ញុំសូមបញ្ជាប់សារជាថ្មីម្តងទៀត ហើយការបញ្ជាក់នេះគឺបាន អះអាងជាមួយឯកឧត្តមរដ្ឋមន្ត្រីការបរទេសរបស់មីយ៉ាន់ម៉ាផងដែរថា កម្ពុជា និងក្នុងរូបខ្ញុំផ្ទាល់ជាប្រេសិតពិសេសរបស់ប្រធានអាស៊ាន នឹង ប្រឹងប្រែងឲ្យអស់ពីសមត្ថភាព និងលទ្ធភាពដែលយើងមាន ដើម្បីជួយ ប្រទេស និងប្រជាជនមីយ៉ានម៉ា ដរាបណាឯកភាពផ្ទៃក្នុងរបស់អាស៊ាន ត្រូវបានរក្សាឲ្យនៅគង់វង្ស ដើម្បីជាប្រយោជន៍សម្រាប់ប្រជាជន និង តំបន់ទាំងមូល។ មានការឯកភាពក្នុងការប្តេជ្ញាចិត្តខ្ពស់ចំពោះការរក្សា ឯកភាពរបស់អាស៊ានឱ្យនៅគង់វង្ស ទោះនៅក្នុងកាលៈទេសៈណាក៏ ដោយ ទោះយើងត្រូវបំពេញភារកិច្ចណាក៏ដោយ ដោះស្រាយបញ្ហាឬ វិបត្តិណាក៏ដោយ ក៏ឯកភាពអាស៊ាននេះមិនត្រូវបែកបាក់នោះឡើយ។

៤០. ខ្ញុំ និងក្រុមការងារទាំងអស់សូមថ្លែងអំណរគុណចំពោះគ្រប់ដៃ គូ និងមិត្តទាំងអស់ ចំពោះការយកចិត្តទុកដាក់ស្តាប់នូវទស្សនៈរបស់ យើងខ្ញុំ និងភាពអត់ធ្មត់ តាមរយៈការផ្តល់ឱ្យយើងខ្ញុំនូវពេលវេលា លំហ និងការយោគយល់ ដែលមានអត្ថន័យខ្លាំងសម្រាប់ពួកយើង។

៤១. សូមអរគុណ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ចំពោះការយកចិត្តទុកដាក់ស្តាប់។

***********